**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

## *សាររំលែកមរណទុក្ខ*

## *ជូនចំពោះ ក្រុមគ្រួសារសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា*

*សម្ដេចវិបុលសេនាភក្ដី* និង *លោកជំទាវ* ជាទីគោរពរាប់អាន

ខ្ញុំ និង ភរិយានៃខ្ញុំ ព្រមទាំងសមាជិក សមាជិកានៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ មានទុក្ខយ៉ាងក្រៀមក្រំ ដោយបានទទួលដំណឹងថា មហាឧបាសក *គង់ ខាត់* ត្រូវជាបិតាបង្កើតនៃលោកជំទាវ *អ៊ឹង សាន* ឧត្តមភរិយានៃ *សម្ដេច* បានទទួលអនិច្ចកម្មទៅ នៅថ្ងៃអាទិត្យ ៦រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី៧ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង០៥:៣៦នាទីទាបភ្លឺ ក្នុងជន្មាយុ១០១ ឈានចូល១០២ឆ្នាំ ដោយជរាពាធ។ ការបាត់បង់រូបមហាឧបាសកនាពេលនេះ មិនត្រឹមជាការបាត់បង់របស់ក្រុមគ្រួសារ *សម្ដេច* និង *លោកជំទាវ* នោះទេ តែគឺជាការបាត់បង់របស់យើងទាំងអស់គ្នានូវព្រឹទ្ធាចារ្យប្រកបដោយជន្មាទិឃាយុ គួរជាទីគោរពដ៏កម្រក្នុងពេលបច្ចុប្បន្ន។

នៅក្នុងឱកាសដ៏សោកសៅនេះ ខ្ញុំ និងភរិយានៃខ្ញុំ ព្រមទាំងសមាជិក សមាជិកានៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ សូមគោរពចូលរួមមរណទុក្ខដ៏សែនក្រៀមក្រំជាមួយ *សម្ដេច* និង *លោកជំទាវ* ព្រមទាំងក្រុមគ្រួសារទាំងមូល ចំពោះការបាត់បង់ដ៏ធំធេងនេះ និងសូមបួងសួងដល់បដិសន្ធិវិញ្ញាណរបស់មហាឧបាសក *គង់ ខាត់* សូមបានអញ្ជើញដល់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម *សម្ដេចវិបុលសេនាភក្ដី* និង *លោកជំទាវ* មេត្តាទទួលនូវការគោរពរាប់អាន និងសមានចិត្តចូលរួមរំលែកមរណទុក្ខ ដោយសេចក្ដីក្រៀមក្រំ ពីខ្ញុំ។

ថ្ងៃអាទិត្យ ៦រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៨

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**អ៊ឹម ឈុនលឹម**

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១ ២៣ ៧២០ ៩១៣, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh , ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ